**ការទទួលស្គាល់រដ្ឋ (recognition of State)**

ពាក្យការទទួលស្គាល់នេះ សំដៅការទទួលស្គាល់ដោយរដ្ឋាភិបាលនៃរដ្ឋដល់រដ្ឋថ្មី ឬរដ្ឋាភិបាលដែលកើតក្នុងរដ្ឋមានស្រាប់ ក្នុងលក្ខណៈមិនប្រក្រតី។ ការទទួលស្គាល់រដ្ឋ នាំឲ្យមានការទទួលស្គាល់នូវកម្មសិទ្ធិដែនដី (territorial title) ឬកិច្ចរដ្ឋបាល ជាដើម។

ការទទួលស្គាល់ អាចភ្ជាប់ជាមួយលក្ខខណ្ឌ ដូចជា តម្រូវឲ្យរដ្ឋាភិបាលនោះ គោរពសិទ្ធិមនុស្សជាដើម។ ទោះបីជាយ៉ាងនេះ ក្នុងករណីមិនគោរព ក៏មិនមានន័យថា ដកការទទួលស្គាល់ដែរ លើកលែងមានការដកការទទួលស្គាល់ជាក់ស្តែង។

ការទទួលស្គាល់រដ្ឋ និងរដ្ឋាភិបាលក្តី ធ្វើឡើងតាមវិធីផ្សេងៗ ដោយជាកលាក់ ឬ ដោយប្រយោល។ ជាក់លាក់ សំដៅថា មានឯកសារ ដូចជាសន្ធិសញ្ញា ចែងច្បាស់ក្នុងការទទួលស្គាល់ ឬ តាមរយៈសកម្មភាពដូចជា ការផ្លាស់ប្តូរតំណាងទូត ដែលនេះជាការទទួលស្គាល់ដោយប្រយោល។

ការទទួលស្គាល់ផ្អែកលើទ្រឹស្តីចំនួនពីរ៖ constitutive theory និង declaratory theory។ ផ្អែកតាមទ្រឹស្តីទី១ នៅពេលរដ្ឋបានបង្កើតហើយ វាក្លាយជារដ្ឋ ដែលមានសិទ្ធិ និងភាតព្វកិច្ច (international personality) មិនទាមទារឲ្យមានរដ្ឋដទៃទទួលស្គាល់ទេ។ ចំណែកទ្រឹស្តីទី២ ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងស្រុក រដ្ឋត្រូវធ្វើសេចក្តីប្រកាសជាលាយលក្ខអក្សរ។ ជាក់ស្តែងការអនុវត្តរបស់ចក្រភពអង់គ្លេស ពាក់ព័ន្ធនឹងការទទួលស្គាល់ក្នុងលក្ខខណ្ឌ៖ ១. រដ្ឋ ឬ រដ្ឋាភិបាល មានសមត្ថភាពក្នុងការប្តឹង។ ២. មានអភ័យឯកសិទ្ធិក្រោយពីរដ្ឋនោះត្រូវបានទទួលស្គាល់ និងទី៣. កិច្ចផ្លូវច្បាប់ ឬរដ្ឋបាលនឹងត្រូវទទួលស្គាល់ ក្រោយពេលរដ្ឋនោះត្រូវបានទទួលស្គាល់ (judicial act is in principle entitled to credence only if it be recognized) (John P. Grant and J. Craig Barker, Encyclopedia Dictionary of International law, 3rd Ed., 2009, pp. 502-508)។